**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សាលក្រមព្រហ្មទណ្ឌ

-លេខ ១៣៣ ក្រ៩ "ខ"

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៦៩

ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ៣៥៣៨

ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៤៤៤៥

ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៨ព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាពជំនុំជម្រះ ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៦៩ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបររើសអេតចាយ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] ខេត្តតាកែវ ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវលំ ក្រុម៩ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ាប់ "ស្លាប់" ម្តាយឈ្មោះ [redacted] ស្រីមុំ "រស់" នៅលីវ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ឃុំខ្លួននៅម១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៨៧០ "ជ"ដឃដ/០៤.១១.២០២១

**-ដោយចាត់តាំងកញ្ញាមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។**

ជាប់ចោទពីបទ ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់ទ្វារបន្ទប់ជួលលួចយកទ្រព្យសម្បត្តិជនរងគ្រោះ)** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលគ្មានលេខ ផ្លូវលំ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

ជនរងគ្រោះឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះជួលគ្មានលេខ ផ្លូវលំ ក្រុមទី៦ ភូមិព្រែកទាល់ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## **អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ ជនរងគ្រោះឈ្មោះ [redacted]ពិសិដ្ឋ បានចាក់សោរទ្វារបន្ទប់ជួលស្ថិតនៅផ្លូវលំ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីទៅចូលរួមបុណ្យម្ដាយមិត្តភក្តិ ។ លុះដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ជនរងគ្រោះបានត្រឡប់មកវិញឃើញទ្វារបន្ទប់ជួលចំហរក៏បានចូលមើលឃើញមានបាត់ទ្រព្យសម្បត្តិមួយចំនួនដូចជា ត្បូងទទឹមពណ៌ក្រហមចំនួន២គ្រាប់ គ្រឿងភ្លុក និងចែកាច់មួយចំនួន ខ្សែអង្កាំមួយចំនួន និងបន្តោងខ្សែកធ្វើពីឈើមួយចំនួនទៀត បន្ទាប់មកជនរងគ្រោះក៏បានដាក់ពាក្យបណ្ដឹងតែម្ដង ។ លុះដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ សមត្ថកិច្ចបានស្រាវជ្រាវនិងឃាត់ខ្លួនជនសង្ស័យឈ្មោះ[redacted] រតនា ហើយជនជាប់ចោទរូបនេះបានឆ្លើយសារភាពថាមានបក្ខពួក២នាក់ទៀតឈ្មោះ វីត និងឈ្មោះ អូន ដោយបានធ្វើសកម្មភាពយកកន្ត្រៃកាត់សោរទ្វារបន្ទប់ជនរងគ្រោះលួចយកទ្រព្យសម្បត្តិប្រាកដមែន ហើយទ្រព្យសម្បត្តិទាំងនោះយកទៅផ្ញើនៅផ្ទះរបស់ឈ្មោះ តាក់ ។

-បានឃើញរបាយការណ៍សំយោគលេខ ១២១ របក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៥៩៥ អយឈ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៣៦០ អយឈ ចុះថ្ងៃ០៩ ខែធ្នូ ឆ្នាំ២០២១ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨៣០ “ជ”ដជ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ[redacted] **រតនា** បានឆ្លើយថា៖ ខ្ញុំទទួលយកការចោទប្រកាន់ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ម៉ោង១រំលងអាធ្រាត្រ ពេលខ្ញុំកំពុងរៀបចំរទេះអេតចាយ ស្រាប់តែឈ្មោះ វីត និងអូនតូច បានបបួលខ្ញុំដើរលួចទ្រព្យសម្បត្តិគេ ហើយខ្ញុំបានយល់ព្រម ។ ពេលមកដល់ផ្ទះជនរងគ្រោះឈ្មោះ អូនតូច បានយកកន្ត្រៃតូចដែលនៅក្នុងលាក់ទុកក្នុងខ្លួនមកផ្ដិះសោរទ្វារបន្ទប់ ដោយខ្ញុំជាអ្នកចាំមើលផ្លូវ ពេលផ្ដិះរួចហើយពួកខ្ញុំទាំងបីនាក់បានចូលក្នុងបន្ទប់នោះនិងលួចទ្រព្យសម្បត្តិរួមមានព្រះផ្លាក់អំពីឈើប្រហែល៣០អង្គ និងមួយប្រអប់ទៀតមានចង្កូមសត្វ និងត្បូងមួយចំនួន ហើយពួកខ្ញុំក៏ត្រឡប់ទៅផ្ទះរៀងខ្លួន ។ លុះស្អែកឡើង ខ្ញុំបានយកប្រអប់ឈើ និងចង្កូមសត្វ និងត្បូងមួយប្រអប់ទៅទុកនៅផ្ទះរបស់ឈ្មោះ តាក់ ហើយនៅម៉ោងប្រហែល១១ថ្ងៃត្រង់ពេលខ្ញុំដើរតាមផ្លូវស្រាប់តែសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំតែម្ដង ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានឃើញថាជនជាប់ចោទបានឆ្លើយសារភាព ដូចនេះសុំតម្កល់បទចោទដូចក្នុងដីកាសន្និដ្ឋានស្ថាពរ និងសុំឱ្យចៅក្រមពិចារណាតាមច្បាប់ ។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានកូនក្តីខ្ញុំបានឆ្លើយសារភាពនិងសន្យាកែប្រែខ្លួន និងទើបប្រព្រឹត្តបទល្មើសលើកទី១ ហើយកូនក្តីខ្ញុំរៀនត្រឹមថ្នាក់ទី៨ចំណេះដឹងមានកំរិតនិងបញ្ញាជីវភាពទើបប្រព្រឹត្តដូច្នេះ ។ ដូចនេះសុំឱ្យផ្តល់ស្ថានសម្រាលដល់កូនក្តីខ្ញុំ ។

-ជនជាប់ចោទឈ្មោះ [redacted] **រតនា** សំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**<u>យល់ឃើញថា</u>**

-កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស** មួយបានកើតឡើងនៅចំណុចបន្ទប់ជួលគ្មានលេខ ផ្លូវលំ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២១ឆ្នាំ និងបក្ខពួកបានធ្វើសកម្មភាពគាស់ទ្វារបន្ទប់ជួលរបស់ជនរងគ្រោះលួចយកទ្រព្យសម្បត្តិមួយចំនួនប្រាកដមែន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **រតនា** ឆ្លើយថាខ្លួននិងបក្ខពួកពិតជាបានគាស់ទ្វារបន្ទប់របស់ជនរងគ្រោះលួចយកទ្រព្យសម្បត្តិប្រាកដមែន ។ ឃើញថាចម្លើយនេះមានភាពស៊ីសង្វាក់នឹងចម្លើយដែលបានឆ្លើយគ្រប់ដំណាក់កាល ដូចនេះចម្លើយរបស់ជនជាប់ចោទនាពេលសវនាការអាចឱ្យតុលាការជឿជាក់បាន ។

-តាមពាក្យបណ្តឹងរបស់ជនរងគ្រោះឈ្មោះ [redacted] ពិសិដ្ឋ គឺរៀបរាប់ថាវេលាម៉ោង២២និង៤៣នាទីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ ខ្លួនបានទៅចូលរួមបុណ្យសពម្តាយមិត្តភក្តិ ដោយពេលនោះខ្លួនបានចាក់សោរទ្វារផ្ទះត្រឹមត្រូវ ។ លុះព្រឹកស្អែកម៉ោង៦ព្រឹកអ្នកជិតខាងបានទូរស័ព្ទប្រាប់ខ្លួនថាមានចោរគាស់ផ្ទះលួចយកទ្រព្យសម្បត្តិអស់ហើយ បន្ទាប់មកពេលខ្លួនត្រឡប់មកដល់ផ្ទះវិញឃើញទ្វាររបើក ហើយសម្ភារៈបាត់បង់មានដូចជា៖ ត្បូងទទឹមពណ៌ក្រហមចំនួន២គ្រាប់ តម្លៃ ៣៦០០ដុល្លារអាមេរិក, គ្រឿងភ្លុក ចែកាច់ ចំនួន៣ក្រឡ តម្លៃ៧២០០ដុល្លារអាមេរិក, ខ្សែកអង្កាំចំនួន២កាបូបយួរដៃតម្លៃ៧០០ដុល្លារអាមេរិក និងបន្តោងខ្សែកធ្វើពីឈើ១កាបូបតម្លៃ៥០០ដុល្លារអាមេរិក ។ សរុបទឹកប្រាក់ដែលបាត់បង់ចំនួន ១២០០០ដុល្លារអាមេរិក ។

-មានភាពស៊ីសង្វាក់គ្នារវាងចម្លើយរបស់ជនជាប់ចោទ ចម្លើយជនរងគ្រោះ និងតាមការពិនិត្យឯកសារជាភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងអាចឱ្យតុលាការកំណត់បាននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ២១ឆ្នាំ ពិតជាបានយកកន្រ្តៃគាស់ទ្វារបន្ទប់របស់ជនរងគ្រោះចូលលួចយកទ្រព្យសម្បត្តិរបស់ជន



Scanned with CamScanner

រងគ្រោះមួយចំនួនដើម្បីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រាកដមែន ។ អំពើនេះច្បាប់បានកំណត់ជាបទល្មើស **លួចមានស្ថានទម្ងន់ទោស** ដោយមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទជានីតិជនដែលមាននីតិសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យ ថាជននេះមានវិបល្លាសស្មារតីកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតក្នុងលក្ខខណ្ឌនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហេតុនេះត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានភស្តុតាង ពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបររើសអេតចាយ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិនាល ឃុំតាំងដូង ស្រុកបាទីខេត្តតាកែវ ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវលំ ក្រុម៩ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យរាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ាប់ "ស្លាប់" ម្តាយឈ្មោះ [redacted] ស្រីមុំ "រស់" នៅលីវ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ ពីបទ ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់ទ្វារបន្ទប់ជួលលួចយកទ្រព្យសម្បត្តិជនរងគ្រោះ)** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលគ្មានលេខ ផ្លូវលំ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] ពិសិដ្ឋ ពុំបានមកចូលមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការនោះទេ នោះគប្បីមិនលើកយកបញ្ហាសំណងរដ្ឋប្បវេណីមកពិចារណាឡើយ ។

-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានគឺសុំរក្សាការចោទប្រកាន់លើឈ្មោះ[redacted] រតនា ពីបទ លួចមានស្ថានទម្ងន់ទោស ឃើញថាមានភស្តុតាងគ្រប់គ្រាន់ ដូចនេះគប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមច្បាប់ ។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] គឺកូនក្តីខ្លួនបានឆ្លើយសារភាពនិងសន្យាកែប្រែខ្លួន និងទើបប្រព្រឹត្តបទល្មើសលើកទី១ ហើយរៀនត្រឹមថ្នាក់ទី៨ចំណេះដឹងមានកំរិតនិងបញ្ហាជីវភាពទើបប្រព្រឹត្តដូច្នេះ ដូចនេះសុំផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ។ ដូចនេះគប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ[redacted] **រតនា** បានសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោស ដូចនេះតុលាការនឹងពិចារណាតាមច្បាប់ ។

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤(បួន)ឆ្នាំ ពីបទ ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (គាស់ទ្វារបន្ទប់ជួលលួចយកទ្រព្យសម្បត្តិជនរងគ្រោះ)** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលគ្មានលេខ ផ្លូវលំ ភូមិព្រែកទាល់១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |

ហត្ថលេខា និងត្រា៖ [redacted]

---

*"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"*

ថ្ងៃពុធ៧កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]